# មេរៀនទី ១១៧៖ ព្រះយេស៊ូវប្រទានពរដល់ក្មេងៗ

## ម៉ាកុស ១០៖១៣-១៦

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/iWs3r6QEhRE

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/oLD9kyRNBp8

**គោលបំណង៖** ព្រះស្រលាញ់ក្មេងៗ។

**ខគម្ពីរចងចាំ៖** ម៉ាកុស ១០៖១៤ខ *"ទុកឲ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរព្រះមានសុទ្ធតែមនុស្សដូចវារាល់គ្នាដែរ។"*

**ចំរៀង** ( *យូធូបលីង* )៖
១.ក្ដីស្រឡាញ់នៃព្រះផ្ទៃមហើយអស្ចារ្យ https://youtu.be/W7hfRd0undE
២.ព្រះយេស៊ូវស្រឡាញ់កុមារណាស់ https://youtu.be/8iUI62Zo_Co
៣.ព្រះយេស៊ូវស្រឡាញ់ខ្ញុំណាស់ https://youtu.be/R4MEw0jzZ_E

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** **«គ្រួសារក្នុងព្រះគ្រីស្ទ»**

សម្ភារៈដែលត្រូវការ៖ ក្រមា



១. ចែកកុមារជា២-៣ក្រុម ហើយឲ្យក្រមាទៅក្រុមនីមួយៗ
២. គោលបំណងនៃល្បែងនេះគឺ ដើម្បីធ្វើឱ្យប្រាកដថាកុមារគ្រប់គ្នាឈរនៅលើក្រមា ដោយមិនប៉ះដី។
៣. នៅពេលដែលគ្រូប្រាប់ការណែនាំ ក្រុមនីមួយៗ ត្រូវបត់ក្រមានោះពាក់កណ្ដាល។ បន្តបត់ក្រមានោះពាក់កណ្ដាលរហូតដល់ក្រមានោះតូចជាងមុន កុមារត្រូវតោងគ្នាឱ្យជាប់ ធ្វើយ៉ាងណាដើម្បីកុំឲ្យប៉ះដី។



៤.ក្រុមណាដែលអាចឈរនៅលើក្រមានោះបានទាំងអស់គ្នា ដោយមិនប៉ះដីនោះក្រុមរបស់ពួកគេនឹងឈ្នះល្បែងនេះ។
៥. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា យើងត្រូវជួយគ្នាទៅវិញទៅមក ដើម្បីយើងទាំងអស់គ្នាអាចរៀនពីសេចក្តីស្រឡាញ់របស់ព្រះវរបិតានៃយើង។ ព្រះស្រឡាញ់កុមារ ហើយយើងត្រូវប្រាប់អ្នកដទៃអំពី សេចក្តីស្រលាញ់នោះដែរ!

**៤. ការណែនាំមេរៀន**

តើអ្នកណាជាមនុស្សសំខាន់ជាងគេនៅក្នុងប្រទេសកម្ពុជា? តើនរណាដែលសំខាន់ជាងគេនៅក្នុងភូមិរបស់ប្អូន នៅក្នុងក្រុមគ្រួសាររបស់ប្អូន និងនៅក្នុងសាលារបស់ប្អូន? ហេតុអ្វីបានជាពួកគេសំខាន់? មនុស្សគឺខ្វល់ខ្វាយ តែពីបុគ្គលដែលសំខាន់តែប៉ុណ្ណោះ។ តើព្រះស្រលាញ់តែអ្នកដែលសំខាន់មែនដែរ

ឬទេ? អត់ទេ! ព្រះគឺ ស្រលាញ់មនុស្សគ្រប់គ្នា សូម្បីតែក្មេងៗផងដែរ! ថ្ងៃនេះយើងនឹងរៀនអំពីព្រះយេស៊ូវ ដែលទ្រង់បាន បង្ហាញសេចក្ដីស្រលាញ់របស់ទ្រង់ចំពោះក្មេងៗ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះយេស៊ូវគឺជាបុគ្គលដ៏សំខាន់នៅក្នុងជំនាន់ព្រះគម្ពីរសញ្ញាថ្មី។ មនុស្សគ្រប់គ្នាចង់ជួបទ្រង់ និងរៀនសូត្រពីព្រះអង្គ។ ពួកគេក៏ចង់ឲ្យព្រះអង្គប្រទានពរ និងព្យាបាលដល់ពួកគេដែរ។ មានការអស្ចារ្យជាច្រើន ដែលព្រះយេស៊ូវបានធ្វើ ហើយក៏មានមនុស្សជាច្រើនបានមកជួបទ្រង់ផងដែរ។

ពេលមួយដែលព្រះយេស៊ូវកំពុងតែរវល់ក្នុងការបង្រៀន មានឪពុកម្ដាយរបស់ក្មេងខ្លះ ចង់ឲ្យព្រះយេស៊ូវប្រទានពរដល់កូនៗរបស់ពួកគាត់។ ប៉ុន្ដែពួកសិស្សរបស់ព្រះយេស៊ូវ គិតថាព្រះយេស៊ូវកំពុងរវល់ ដូច្នេះពួកគេបានប្រាប់ទៅឪពុកម្ដាយឲ្យនាំក្មេងៗត្រឡប់ទៅវិញ។ នៅពេលដែលព្រះយេស៊ូវបានឮថាឲ្យនាំក្មេងៗត្រឡប់ទៅវិញនោះ ទ្រង់មិនសប្បាយចិត្តនោះទេ! ទ្រង់ក៏មានបន្ទូលថា ព្រះគម្ពីរ **ម៉ាកុស ១០៖១៤ខ**
“ទុកឲ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរព្រះមានសុទ្ធតែមនុស្ស ដូចវារាល់គ្នាដែរ។”

ពេលនោះ ក្មេងៗបានចូលទៅឯព្រះយេស៊ូវយ៉ាងសប្បាយរីករាយ ហើយទ្រង់ក៏លេង និងសើចជាមួយពួកគេផងដែរ។ ព្រះគម្ពីរចែងថា ព្រះយេស៊ូវបានឱបក្មេងៗនៅក្នុងព្រះហស្ដទ្រង់! សូមស្រមៃថាពេលព្រះយេស៊ូវលើកអ្នកឡើង ហើយឱបអ្នកនោះ តើអ្នកមានអារម្មណ៍ដូចម្ដេច? ព្រះយេស៊ូវចង់បង្ហាញអ្នករាល់គ្នាថា ទ្រង់ស្រឡាញ់ក្មេងៗ!

ព្រះយេស៊ូវស្រលាញ់អ្នក! សម្រាប់អ្នក ទ្រង់មិនដែលនិយាយពាក្យថារវល់នោះទេ ហើយទ្រង់សព្វព្រះទ័យក្នុងការចំណាយពេលជាមួយអ្នក។ អ្នកអាចរត់ទៅរកព្រះបានគ្រប់ពេលដែលអ្នកចង់ ហើយទ្រង់តែងតែប្រុងប្រៀបស្ដាប់អ្នកជានិច្ច ទ្រង់នឹងឱបអ្នកក្នុងព្រះហស្ដរបស់ទ្រង់។ ជាការពិត ព្រះយេស៊ូវចង់ឲ្យយើងរស់នៅជាមួយទ្រង់ជារៀងរហូតក្នុងនគររបស់ទ្រង់។ ប៉ុន្ដែមនុស្សគ្រប់គ្នាមិនបានដឹងទេថា ព្រះយេស៊ូវស្រលាញ់ក្មេងៗ! ពួកយើងគួរតែប្រាប់មិត្តភក្ដិរបស់យើងថា ព្រះយេស៊ូវស្រលាញ់ពួកគេ ដូច្នេះពួកគេក៏អាចចូលក្នុងនគររបស់ព្រះជាមួយពួកយើងដែរ!

## ៦. សំនួរពិភាក្សា

១. ហេតុអ្វីបានជាមនុស្សម្នាចង់ជួបព្រះយេស៊ូវ?
*(ដើម្បីរៀនពីទ្រង់, សុំព្រះពរ, ការប្រោសឲ្យជា និងការអស្ចារ្យផ្សេងៗទៀត)*
២. តើនរណាដែលប្រាប់ឲ្យក្មេងៗត្រឡប់ទៅវិញនោះ? *(ពួកសិស្សរបស់ព្រះយេស៊ូវ)*
៣. តើនរណាដែលបានខឹងនៅពេលដែលឮពួកសិស្សប្រាប់ឲ្យក្មេងៗត្រឡប់ទៅវិញនោះ? *(ព្រះយេស៊ូវ)*
៤. តើព្រះយេស៊ូវបានធ្វើដូចម្ដេចនៅពេលដែលក្មេងៗមកឯទ្រង់?
*(ព្រះអង្គបានឱបពួកគេដោយព្រះហស្ដទ្រង់ និងបានប្រទានពរដល់ពួកគេ)*
៥. តើអ្នកគួរប្រាប់អំពីព្រះយេស៊ូវដល់អ្នកណា ដើម្បីឲ្យពួកគេអាចទទួលបានសេចក្ដីស្រលាញ់ពីព្រះយេស៊ូវដែរនោះ?(ទុ*កឲ្យកុមារជាអ្នកឆ្លើយ)*

## ៧. ល្បែងកំសាន្ត «សាវ័កឃាត់កុមារមិនឲ្យមកជួបព្រះយេស៊ូវ»




១. ជ្រើសរើសកុមារពីរនាក់ ម្នាក់ដើរតួជាព្រះយេស៊ូវ និងម្នាក់ទៀតដើរតួជាសិស្សរបស់ព្រះយេស៊ូវ
២. ព្រះយេស៊ូវត្រូវឈរនៅចុងម្ខាងនៃថ្នាក់រៀន ហើយសិស្សរបស់ព្រះយេស៊ូវឈរនៅប្រហែល ១ម៉ែត្រពីព្រះយេស៊ូវហើយប្រុងប្រៀប

ខ្លួនក្នុងការលេង "ក្រហម បៃតង" ។ កុមារដែលនៅសេសសល់ត្រូវឈរ នៅចុងម្ខាងទៀតនៃថ្នាក់រៀន។



៣. នៅពេលដែលគ្រូស្រែកថា "បៃតង" សិស្សរបស់ព្រះយេស៊ូវ ត្រូវឈរ បែរមុខទៅជញ្ជាំង កុមារដែលនៅសេសសល់អាចដើរឲ្យលឿនទៅរក ព្រះយេស៊ូវបាន។

៤. ប៉ុន្តែប្រសិនបើគ្រូស្រែកថា "ក្រហម" នោះសិស្សរបស់ព្រះយេស៊ូវងាកមកក្រោយ ហើយបើឃើញកុមារ ណាម្នាក់កម្រើកខ្លួន នោះកុមារនោះ ត្រូវតែអង្គុយចុះ។ នៅពេលដែលសិស្សរបស់ព្រះយេស៊ូវ បែរទៅរក ជញ្ជាំងវិញ នោះកុមារទាំងអស់អាចបន្តផ្លាស់ទីទៅរកព្រះយេស៊ូវទៀត។ បន្តលេងល្បែងនេះរហូតដល់ កុមារណាម្នាក់អាចទៅជៀកព្រះយេស៊ូវ និងប៉ះទ្រង់បាន។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះយេស៊ូវគឺស្រលាញ់កុមារគ្រប់ៗគ្នា។

### ៨. ខគម្ពីរចងចាំ

**ម៉ាកុស ១០៖១៤ខ** *"ទុកឲ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរព្រះមានសុទ្ធតែមនុស្សដូចវារាល់គ្នាដែរ។"*

### ៩. ហត្ថកម្ម «ព្រះយេស៊ូវស្រលាញ់ខ្ញុំ»

សម្ភារៈដែលត្រូវការ៖ ព្រីនក្រដាសហត្ថកម្ម

១. ឲ្យក្រដាសហត្ថកម្មទៅកុមារម្នាក់មួយ

២. ប្រាប់ឲ្យកុមារអានខគម្ពីរចងចាំទាំងអស់គ្នា ហើយគូសរូបរបស់ពួកគេ និងរូបព្រះយេស៊ូវ។

### ១០. ចំរៀង (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

### ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ព្រះយេស៊ូវ គឺជាព្រះដ៏មានព្រះចេស្តា ជាព្រះដែលបង្កើតលោកីយ៍ និងឈ្នះសេចក្តីស្លាប់ ទ្រង់យកចិត្តទុកដាក់ចំពោះកូនង៉ែតទាំងអស់ កុមារទាំងអស់ យុវជនទាំងអស់ និងមនុស្សគ្រប់វ័យទាំងអស់។ មនុស្សសំខាន់តែងតែសេពគប់តែជាមួយមនុស្សសំខាន់ដូចគ្នាប៉ុនណ្ណោះ - ពួកគេមិនចង់ខ្ជះខ្ជាយពេលវេលារបស់ពួកគេលើមនុស្សដែលនឹងមិនជួយពួកគេទេ។ ប៉ុន្តែព្រះយេស៊ូវគឺខុសគ្នា! ព្រះយេស៊ូវមានចិត្តស្រឡាញ់ចំពោះអ្នក ហើយចង់ចងមិត្តភាពជាមួយនឹងអ្នក។ ទ្រង់ស្រឡាញ់មនុស្សគ្រប់គ្នាដូចៗគ្នា។ តើអ្នកអាចស្រមៃពីជម្រៅនៃសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទចំពោះអ្នកបានទេ? សូមអានព្រះគម្ពីរ **រ៉ូម ៨៖៣៨-៣៩** ហើយរំឭកខ្លួនអ្នកអំពីសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះចំពោះអ្នក។ រួចគិតអំពីសំណួរនេះ ៖ តើអ្នកបានធ្វើតាមគំរូរបស់ព្រះអម្ចាស់ទេ? តើអ្នកអាចស្រឡាញ់នរណាម្នាក់ ដោយប្រើសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវបានទេ?

# ព្រះយេស៊ូវស្រលាញ់ខ្ញុំ

ម៉ាកុស ១០៖១៤ខ “ទុកឲ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរព្រះមានសុទ្ធតែ មនុស្សដូចវារាល់គ្នាដែរ។”

(សូមគូសរូបរបស់អ្នកនិងរូបព្រះយេស៊ូវ)